ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៙៚✤៛

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៦១៥ អយក-ប្រក

# ប្រកាស

## ស្តីពីការបើកសាលាបឋមសិក្សា ចតុមណ្ឌល

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតលេខ ៣៤៦ អយក.ពវ.បម ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០២ របស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត ព្រៃវែង ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

### សំរេច

**ប្រការ១** :- បើកសាលាបឋមសិក្សា **ចតុមណ្ឌល** ជាផ្លូវការដែលមានទីតាំងស្ថិតនៅភូមិ **ក្រវ៉ាន់** ឃុំ **ក្រញូង** ស្រុក **កំចាយមារ** ខេត្ត **ព្រៃវែង** ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **ចតុមណ្ឌល** ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា។

**ប្រការ៣** :- នាយក នាយករង មានសិទ្ធទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការកំនត់របស់រដ្ឋ។

**ប្រការ៤** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ព្រៃវែង** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កំចាយមារ** នាយកសាលាបឋមសិក្សា **ចតុមណ្ឌល** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០២
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាបជាពត៌មាន"

- សាលាខេត្ត ព្រៃវែង

"ជូនជ្រាបជាពត៌មាន"

- ដូចប្រការ ៥
- កាលប្បវត្តិ - ឯកសារ នា.បម